យូរ៉ាតា (ខេមបូឌា) ឯ.ក
URATA (CAMBODIA) CO., LTD.

ដីឡូត៍លេខ២០០៥ ការិយាល័យលេខ៥១៥ ជាន់ទី៥ ផ្លូវលេខ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
Tel: 023 902 115

1

# ដំណើរការស្តង់ដារដើម្បីទទួលបានលិខិតអនុញ្ញាតសាងសង់




**ខ្លឹមសារការងារបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម និងប្លង់មេកានិក ប្រព័ន្ធទឹក អគ្គិសនីរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ :**

1. ត្រួតពិនិត្យទៅលើផ្នែកនគរូបនីយកម្ម មានជាអាទិ៍ ផ្លាគម្លាត កម្ពស់សំណង់ សន្ទស្សន៍ប្រើប្រាស់ដី ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ការប្រើប្រាស់លំហសាធារណ: ផ្ទៃបៃតង ចំណតយានយន្តក្រៅអគារ។

2. ត្រួតពិនិត្យទៅលើផ្នែកស្ថាបត្យកម្ម មានជាអាទិ៍ ដំបូល ទ្វារ បង្អួច ជណ្តើរ កម្ពស់ ច្រកចេញចូល លំហ ខ្យល់ចេញចូល ពន្លឺ ចំណតយានយន្តក្នុងអគារ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណ:ងាយស្រួលសម្រាប់ជនពិការភាព មុខងារប្រើប្រាស់សំណង់ មុខងារសមាសភាគសំណង់។

3. ត្រួតពិនិត្យទៅលើ ផ្នែកប្រព័ន្ធទឹកកខ្វក់ និងប្រព័ន្ធទឹកភ្លៀង បណ្តាញលូបង្ហូរទឹកកខ្វក់ បណ្តាញលូបង្ហូរទឹកភ្លៀង អាងសិបទិច អាងប្រព្រឹត្តកម្មទឹកកខ្វក់ ទទឹកភ្លៀង អាងស្តុកទឹកភ្លៀង អាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ។

4. ត្រួតពិនិត្យទៅលើ ផ្នែកសុវត្ថិភាព ផែនទីជម្លៀស ច្រកសុវត្ថិភាព ជណ្តើរសង្គ្រោះ បន្ទប់សុវត្ថិភាព អគ្គិភ័យ ឧបករណ៍ការពាររន្ទះ ភ្លើងសញ្ញាអាកាសចលើដំបូលអគារ។

5. ត្រួតពិនិត្យទៅលើ ផ្នែកសម្ភារ:សំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។

* យោងទៅប្រការលេខ១៤ នៃប្រកាសលេខ១០៩


Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.

## ① នីតិវិធីនៃសេវាបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម និងប្លង់មេកានិក ប្រព័ន្ធទឹក អគ្គិសនី សម្រាប់ធ្វើការស្នើសុំលិខិតអនុញ្ញាតសាងសង់

**ការប្រជុំជាមុន**

សូមពិនិត្យទៅលើ「**មូលដ្ឋាននៃដំណើរការដើម្បីទទួលបានលិខិតអនុញ្ញាតសាងសង់**」

※ ឯកសារដែលតម្រូវអោយម្ចាស់សំណង់រៀបចំ និងប្រគល់មកមានដូចខាងក្រោម។

C-5 លិខិតប្រគល់ និងទទួលឯកសារបច្ចេកទេស（ឧបសម្ព័ន្ធទី១） ២ច្បាប់

C-6 លិខិតប្រគល់សិទ្ធិ ១ច្បាប់

C-7 កិច្ចសន្យា（ឧបសម្ព័ន្ធទី៦） ២ច្បាប់

C-8 ឯកសារបច្ចេកទេស

C-8①ប្លង់ទិដ្ឋភាពទូទៅ ឬប្លង់សរុប (Master Plan) មានហត្ថលេខា ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម៦ច្បាប់

C-8②ប្លង់បាតគ្រប់ជាន់, ប្លង់មុខភាព, ប្លង់ពំនុះកាត់ (Layout Plan, View & Section Plan) មានហត្ថលេខា ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម៦ច្បាប់

C-8③ឯកសារសិក្សាភូគព្ភសាស្ត្រ ឬប្លង់ព្រំដី (Survey Plan or Boundary Plan) ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ថតចម្លងជាឯកសាររឹង១ច្បាប់ មានហត្ថលេខាម្ចាស់សំណង់

C-8④រូបភាពនេត្រាទស្សន៍ (3D Views or Perspective View) ជាឯកសាររឹង១ច្បាប់

C-8⑤សេចក្តីណែនាំបច្ចេកទេស ឬបទបញ្ជា (Technical Instruction or Regulation) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹង១ច្បាប់

C-8⑥វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬសលាកបត្រក្បាលដី (Land Title Certificate) ថតចម្លងជាឯកសាររឹង១ច្បាប់ មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់

C-8⑦ប្លង់ប្រព័ន្ធទឹកកខ្វក់ និងប្រព័ន្ធទឹកភ្លៀង (Sewage and Drainage System é Layout and Schematic) មានហត្ថលេខា ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម៦ច្បាប់

C-8⑧ប្លង់អាងសិបទិច ឬប្លង់អាងស្តុកលាមក អាងចម្រោះទឹកកខ្វក់ (Septic Layout and Detail Plan) មានហត្ថលេខាម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម៦ច្បាប់

C-8⑨ប្លង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់ (Sewage Treatment Plan) មានហត្ថលេខា ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសាររឹងច្បាប់ដើម៦ច្បាប់



Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.

C-8⑩ប្លង់អាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ (Wastewater discharge treatment-Process and Drawing Plan) មានហត្ថលេខា ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសារវឹងច្បាប់ដើម០ច្បាប់

C-8⑪ប្លង់អាងស្តុកទឹកភ្លៀង (Rainwater Reservoir Plan drawing) មានហត្ថលេខា ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសារវឹងច្បាប់ដើម០ច្បាប់

C-8⑫ប្លង់ផែនទីជម្លៀស (Evacuation Map drawing) មានហត្ថលេខា ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសារវឹងច្បាប់ដើម០ច្បាប់

C-8⑬ប្លង់ច្រកសុវត្ថិភាព និងជណ្តើរសង្គ្រោះ (Evacuation Plan drawing) មានហត្ថលេខា ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសារវឹងច្បាប់ដើម០ច្បាប់

C-8⑭ប្លង់ឧបករណ៍ការពាររន្ទះ (Lightning Protection System) មានហត្ថលេខា ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសារវឹងច្បាប់ដើម០ច្បាប់

C-8⑮ប្លង់ភ្លើងសញ្ញាអាកាសចរលើដំបូល (Lightning of obstacle for aviation plan drawing) មានហត្ថលេខា ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ ជាឯកសារវឹងច្បាប់ដើម០ច្បាប់

C-8⑯លិខិតបញ្ជាក់ពីលក្ខខណ្ឌពិសេសដែលទទួលបានការអនុញ្ញាតពីស្ថាប័នពាក់ព័ន្ធ ថតចម្លងជាឯកសារវឹង១ច្បាប់ មានហត្ថលេខាម្ចាស់សំណង់

＊សម្រាប់ C-8①②④⑦⑧⑨⑩⑪⑫⑬⑭⑮ សូមភ្ជាប់មកជាមួយនឹងឯកសារច្បាប់ដើម ឯកសារអេឡិចត្រូនិក AutoCAD និង PDF ។

＊សម្រាប់ C-8③⑤⑥⑯ សូមភ្ជាប់មកជាមួយនឹងឯកសារអេឡិចត្រូនិក PDF ។

① ការទទួលអតិថិជន (យើងទទួលតាមរយៈតេលេក្រាមតែប៉ុណ្ណោះ)

ក្នុងករណីធ្វើការស្នើសុំផ្តល់សេវាពីក្រុមហ៊ុនយើងខ្ញុំ សូមធ្វើការបំពេញឯកសារ (ដែលទាញយកពីតំណរGoogle Drive) និងចុះហត្ថលេខា រួចផ្ញើរមកក្រុមហ៊ុនរបស់យើងខ្ញុំតាមរយៈតេលេក្រាមដោយ [ម្ចាស់សំណង់ ឬអ្នកទទួលសិទ្ធិ]។

យើងនឹងទទួលឯកសារដែលប្រគល់មកដូចខាងក្រោម។

C-1 លិខិតទទួល (ពត៌មានម្ចាស់សំណង់, អ្នកសិក្សាគម្រោង, ប្រភេទនៃការបញ្ជាក់, ផ្សេងៗ) ១ច្បាប់

C-2 ពត៌មានគម្រោង (ឈ្មោះគម្រោង, អាសយដ្ឋាន, ផ្ទៃដី, តំបន់ប្រើប្រាស់ដី, ការប្រើប្រាស់អគារ, ផ្ទៃក្រឡាអគារ, ប្រភេទគ្រឿងផ្គុំ និងសូមភ្ជាប់ឯកសារប្លង់ទិដ្ឋភាពទូទៅ Master Plan, ប្លង់បាតគ្រប់ជាន់ layout Plan, ប្លង់មុខភាព View, ប្លង់ពំនុះកាត់ Section Plan, ផែនទីប្រើប្រាស់ដីពិពណ៌នាទីតាំងសំណង់) ១ឈុត

C-6 លិខិតប្រគល់សិទ្ធិ ១ច្បាប់



Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.

② យើងខ្ញុំនឹងធ្វើការជូនដំណឹងវិញអំពី [លិខិតឆ្លើយតបទៅនឹងការផ្តល់សេវា] តាមរយៈតេលេក្រាម។ (ចំណាយពេល៥ថ្ងៃនៃថ្ងៃធ្វើការក្នុងការឆ្លើយតប)

③ ក្នុងករណីធ្វើការស្នើសុំការផ្តល់សេវា សូមធ្វើការដាក់ [លិខិតស្នើសុំផ្តល់សេវា] មកយើងខ្ញុំតាមរយៈតេលេក្រាមក្នុងរយៈពេល៥ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានការជូនដំណឹង [លិខិតឆ្លើយតបទៅនឹងការផ្តល់សេវា] ពីខាងក្រុមហ៊ុន។ (ក្នុងករណីបើលិខិតស្នើសុំផ្តល់សេវាមិនត្រូវបានដាក់មកក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការនោះទេ ការទទួលនឹងត្រូវផុតសុពលភាព)

④ បន្ទាប់ពីដាក់លិខិតស្នើសុំផ្តល់សេវារួច សូមពិនិត្យមើលតារាងឯកសារដែលត្រូវការក្នុងការងារបញ្ជាក់ ។ នៅពេលលោកអ្នកបានរៀបចំឯកសារបានរួចរាល់ សូមធ្វើការណាត់ជួបជាមួយខាងក្រុមហ៊ុនដើម្បីយកឯកសារដែលតម្រូវមកដាក់នៅក្រុមហ៊ុនរបស់យើងខ្ញុំ។

＊របៀបនៃការណាត់ជួបសូមពិនិត្យនៅចំនុច [ករណីមកក្រុមហ៊ុនដើម្បីជួបពិភាក្សា/ពិគ្រោះយោបល់]។

＊តារាងឯកសារត្រូវដាក់

សូមដាក់ឯកសារដូចខាងក្រោម។

| | | | |
|---|---|---|---|
| C-5 | លិខិតប្រគល់ និងទទួលឯកសារបច្ចេកទេស ច្បាប់ដើម (ឧបសម្ព័ន្ធទី១) | ២ច្បាប់ | ហត្ថលេខារបស់ម្ចាស់សំណង់ |
| C-6 | លិខិតប្រគល់សិទ្ធិ ច្បាប់ដើម | ១ច្បាប់ | ហត្ថលេខារបស់ម្ចាស់សំណង់ |
| C-7 | កិច្ចសន្យា ច្បាប់ដើម (បន្ទាប់ពីសរសេរចំនួនទឹកប្រាក់កិច្ចសន្យា និងពេលវេលាបញ្ជាក់) | ២ច្បាប់ | ហត្ថលេខារបស់ម្ចាស់សំណង់ |
| C-8 | ឯកសារបច្ចេកទេស (C-8①~⑯) | | |
| C-3 | លិខិតស្នើសុំផ្តល់សេវា (ច្បាប់ដើម) | ១ច្បាប់ | ហត្ថលេខារបស់ម្ចាស់សំណង់ និងអ្នកសិក្សាគម្រោងប្លង់ |

＊ចំពោះចំនួនទឹកប្រាក់កិច្ចសន្យា និងពេលវេលាបញ្ជាក់មានសរសេរនៅក្នុង [លិខិតឆ្លើយតបទៅនឹងការផ្តល់សេវា]។

⑤ នៅពេលដែលមកដល់ក្រុមហ៊ុន យើងនឹងចេញវិក្កយបត្រស្នើសុំការបង់ប្រាក់ និងលិខិតទទួលឯកសារC-8។

- សូមធ្វើការបង់ប្រាក់ថ្លៃសេវាក្នុងរយៈពេល៤ថ្ងៃនៃថ្ងៃធ្វើការ។
- បន្ទាប់ពីពិនិត្យពីការបង់ប្រាក់រួច យើងនឹងចេញវិក្កយបត្រជូន ហើយនឹងជូនដំណឹងអំពីការបានទទួលប្រាក់ទៅលោកអ្នកវិញតាមរយៈតេលេក្រាម។

⑥ បន្ទាប់ពីទទួលបានទទួលប្រាក់ថ្លៃសេវារួចរាល់ យើងនឹងចាប់ផ្តើមការចុះកិច្ចសន្យា។


Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.

⑦ បន្ទាប់ពីយើងពិនិត្យមើលកិច្ចសន្យារួចរាល់ យើងខ្ញុំនឹងជូនដំណឹងទៅលោកអ្នកតាមរយៈតេលេក្រាមដើម្បីមកទទួលកិច្ចសន្យាពីខាងក្រុមហ៊ុននៅ៣ថ្ងៃបន្ទាប់នៃថ្ងៃធ្វើការ។

⑧ ការចាប់ផ្ដើមកិច្ចសន្យា/ការចាប់ផ្ដើមការងារបញ្ជាក់

- កាលបរិច្ឆេទនៃការចាប់ផ្ដើមការងារ គឺគិតពីថ្ងៃចុះកិច្ចសន្យា(ថ្ងៃទទួលបានប្រាក់ថ្លៃសេវា)។

⑨ បន្ទាប់ពីការងារបញ្ជាក់គម្រោងប្លង់ត្រូវបានបញ្ចប់ យើងនឹងជូនដំណឹងទៅអ្នកដូចខាងក្រោម។

- លិខិតជូនដំណឹងពីការបញ្ចប់ការងារ
- វិក្កយបត្រស្នើសុំការបង់ប្រាក់

＊សូមធ្វើការទូទាត់ប្រាក់ក្នុងរយៈពេល៤ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានឯកសារខាងលើ។

⑩ បន្ទាប់ពីពិនិត្យឃើញថាប្រាក់ត្រូវបានទូទាត់រួច យើងនឹងធ្វើការជូនដំណឹងទៅវិញតាមរយៈតេលេក្រាមអំពីការមកទទួល ឯកសាររបាយការណ៍។ ដូចនេះសូមអញ្ជើញមកទទួលឯកសារពីខាងក្រុមហ៊ុននៅ៣ថ្ងៃបន្ទាប់នៃថ្ងៃធ្វើការ បន្ទាប់ពីការជូនដំណឹង ។

**កំណត់ចំណាំ**

＊ចំពោះការមកក្រុមហ៊ុនក្រៅពីចំណុចទី⑦・⑩ សូមធ្វើការណាត់ជួបនឹងកំណត់ថ្ងៃជាមុន។ ក្នុងករណីមិនមានការណាត់ជួបមុននោះទេ យើងខ្ញុំមិនទទួលជួបនោះឡើយ។

## កំណត់ចំណាំ

＊ការស្នើសុំគឺធ្វើដោយម្ចាស់សំណង់ ឬអ្នកដែលបានទទួលសិទ្ធិពីម្ចាស់សំណង់។ ចំពោះអ្នកផ្សេងទៀតគឺមិនអាចធ្វើការស្នើសុំបានឡើយ។

＊យើងមិនទទួលយកការបង់ថ្លៃសេវាផ្ទាល់នៅការិយាល័យឡើយ។

＊ក្នុងករណីការងារសាងសង់បានចាប់ផ្ដើមរួចហើយ ការងារបញ្ជាក់នឹងមិនត្រូវបានទទួលយកទេ។

＊ក្នុងករណីដូចខាងក្រោម [ការផ្អាកការងារ/ការបញ្ចប់កិច្ចសន្យា] នឹងត្រូវបានអនុវត្ត ហើយប្រាក់ដែលបង់រួចមិនត្រូវបានសងត្រឡប់ទៅវិញឡើយ។

① ក្នុងករណីកិច្ចសន្យាត្រូវបានលុបចោលដោយសារតែមូលហេតុរបស់ម្ចាស់សំណង់។ ចំពោះប្រាក់ដែលបានទូទាត់រួចលើកទីមួយបន្ទាប់ពីចុះកិច្ចសន្យានឹងមិនត្រូវបានសងត្រឡប់ទៅវិញឡើយ។

② ក្នុងករណីរយៈពេលនៃការទូទាត់ប្រាក់លើកទី២លើសពី៧ថ្ងៃនៃថ្ងៃធ្វើការ (កិច្ចសន្យានឹងត្រូវលុបចោល)។

③ ប្រសិនបើការងារសាងសង់ត្រូវបានចាប់ផ្ដើមមុននឹងបញ្ចប់ការងារបញ្ជាក់ យើងនឹងជូនដំណឹងទៅក្រសួងដែនដី (កិច្ចសន្យានឹងត្រូវលុបចោល)។


Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.

④ ក្នុងករណីឯកសារ និងគម្រោងប្លង់សម្រាប់ការបញ្ជាក់ដែលបានដាក់មកមិនពិត (កិច្ចសន្យានឹងត្រូវបានលុបចោល)

⑤ ក្នុងករណីប្រសិនបើរកឃើញថាមានភាពមិនអនុលោម យើងខ្ញុំនឹងចេញ [លិខិតជូនដំណឹងពីភាពខ្វះខាត]។

⑥ ក្នុងករណីមិនមានការកែតម្រូវទៅតាមពេលវេលាដែលបានកំណត់ បន្ទាប់ពីថ្ងៃចេញ [លិខិតជូនដំណឹងអំពីភាពខ្វះខាត] យើងនឹងចេញ [លិខិតស្តីពីភាពមិនអនុលោម]។

⑦ ក្នុងករណីមិនមានការកែតម្រូវទៅតាមពេលវេលាដែលបានកំណត់ បន្ទាប់ពីថ្ងៃចេញ [លិខិតជូនដំណឹងអំពីភាពខ្វះខាត] [លិតបញ្ជាក់ពីអនុលោមភាព] នឹងត្រូវបានបញ្ជាក់ជាលិខិតមិនអនុលោមភាព។ ក្នុងករណីការបញ្ជាក់ជាភាពមិនអនុលោមក៏ដោយ ក៏តម្រូវអោយមានការបង់ប្រាក់ថ្លៃសេវាដែលនៅសល់ដែរ។

⑧ ក្នុងអំឡុងពេលការងារកែតម្រូវរបស់អតិថិជន គឺមិនរាប់បញ្ចូលពេលវេលាអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់ឡើយ។

## ក្នុងករណីមកដល់ក្រុមហ៊ុនដើម្បីធ្វើការពិភាក្សា និងសួរសំណួរ

ដើម្បីកាត់បន្ថយពេលវេលានៃការរង់ចាំនៅពេលដែលមកដល់ក្រុមហ៊ុនអោយមានរយៈពេលខ្លី យើងបានរៀបចំប្រព័ន្ធនិងរបៀបនៃការណាត់ជួបដើម្បីអោយការទទួលមានភាពរលូនផងដែរ។ ដូច្នេះសូមធ្វើការណាត់ជួបទៅតាមការណែនាំដូចខាងក្រោម។

យើងខ្ញុំមិនទទួលការសួរសំណួរតាមរយៈទូរស័ព្ទឡើយ។

① បន្ទាប់ពីបំពេញពត៍មានដែលត្រូវការក្នុងលិខិតណាត់ជួបរួច សូមផ្ញើរមកយើងខ្ញុំតាមរយៈតេលេក្រាម។

② យើងនឹងផ្ញើរលិខិតជូនដំណឹងអំពីការណាត់ជួបទៅអ្នកវិញតាមរយៈតេលេក្រាម។

※ ដោយសារតែយើងត្រូវមានការរៀបចំបុគ្គលិកដែលត្រូវជួបជាមួយអ្នកទៅតាមខ្លឹមសារនៃការពិភាក្សា ដូចនេះសូមសរសេរខ្លឹមសារនៃការណាត់ជួបអោយបានច្បាស់លាស់។

※ ដោយសារតែយើងមានការណាត់ជួបជាមួយនឹងអតិថិជនផ្សេងៗទៀត ដូចនេះការពិភាក្សាអាចមានរយៈពេលត្រឹម៥០នាទីប៉ុណ្ណោះ។

※ ក្នុងករណីប្រសិនបើកាលបរិច្ឆេទដែលលោកអ្នកដាក់មកយើងមិនអាចណាត់ជួប ឬបំពេញតាមសំណើររបស់លោកអ្នកបាន សូមមេត្តាស្នើការណាត់ជួបនៅថ្ងៃផ្សេងម្តងទៀត។

※ ចំពោះការណាត់ជួបដើម្បីពិភាក្សាឬសួរសំណួរ សូមស្នើការណាត់ជួបមកយើងខ្ញុំមុន៥ថ្ងៃនៃថ្ងៃធ្វើការ។



Address: Lot No. 2005, Office No. 515, 5th Floor, Street 307, Sangkat Khmuonh, Khan Sen Sok, Phnom Penh, Cambodia.